ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងស្រូបទោស
លេខ: ១៥០
ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩
សាលដីកាស្រូបទោស
លេខ: ៧៩ V
ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើពាក្យសុំស្រូបទោស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ទិរៈ ហៅ រ៉េត្យ ក្នុងសំណុំរឿងព្រហ្មទណ្ឌស្រូបទោសលេខ១៥០ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់តុលាការកំពូល ដែលមាន៖

-ទណ្ឌិតឈ្មោះ [redacted] ទិរៈ ហៅ រ៉េត្យ ភេទប្រុស អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប កើតនៅ [redacted] ខេត្តកំពង់ឆ្នាំង មានទីលំនៅ [redacted]



Scanned with CamScanner

[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១ នៅពន្ធនាគារខេត្តកណ្តាល។ (អ្នកដាក់ពាក្យសុំ)

-មានមេធាវីការពារសិទ្ធិលោក [redacted] ឌេខ

តាមពាក្យបណ្តឹងសុំស្រូបទោស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ទិរៈ ហៅ វត្ស បានបញ្ជាក់ថា ខ្ញុំបាទត្រូវបានតុលាការនៃសាលាដំបូងរាជធានីភ្នំពេញ សាលាឧទ្ធរណ៍ និងតុលាការកំពូល ផ្តន្ទាទោសតាមសាលក្រម និងសាលដីកា០២ ដាច់ដោយឡែកពីគ្នា ពីបទល្មើសតែមួយដូចគ្នា ដោយផ្តន្ទាទោសខ្ញុំបាទដាក់ពន្ធនាគារកំណត់រយៈពេល០៨(ប្រាំបី)ឆ្នាំ ក្នុងសាលដីកានីមួយៗ បូកសរុបសាលដីកាទាំងពីរ គឺស្មើរនិង ១៦(ដប់ប្រាំមួយ)ឆ្នាំ ហើយបច្ចុប្បន្ននេះខ្ញុំបាទបានអនុវត្តទោសក្នុងពន្ធនាគារបានចំនួន៨(ប្រាំបី)ឆ្នាំហើយ។ ប៉ុន្តែតុលាការចុងក្រោយដែលត្រូវសម្រេចពុំបានប្រកាសឱ្យខ្ញុំបាទអនុវត្តទោសស្រូបបញ្ចូលគ្នាទេ បានជាពេលនេះខ្ញុំបាទដាក់ពាក្យសុំឱ្យ ឯកឧត្តមប្រធាន មេត្តាសម្រេចស្រូបទោសបញ្ចូលគ្នាឱ្យខ្ញុំបាទ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាសម្រេចតាមការស្នើសុំរបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។

-បានឃើញសាលដីកាព្រហ្មទណ្ឌស្តាពរលេខ៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់តុលាការកំពូល បានសម្រេចតម្កល់សាលដីកាលេខ៣៩ ក្រIV"វ" ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ទិរៈ ហៅ វត្ស ដាក់ពន្ធនាគារកំណត់ចំនួន ០៨ឆ្នាំ (ប្រាំបីឆ្នាំ) ពីបទៈ សមគំនិតក្នុងអំពើកំហែងយកមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ និងបទៈ សមគំនិតក្នុងអំពើកាន់កាប់អាវុធដោយគ្មានការអនុញ្ញាតប្រព្រឹត្តនៅសួនច្បារវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន វត្តភ្នំ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌស្តាពរលេខ២២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ របស់តុលាការកំពូល បានសម្រេចតម្កល់សាលដីកាលេខ៤០ ក្រIV"វ" ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ទិរៈ ហៅ វត្ស ដាក់ពន្ធនាគារកំណត់ចំនួន ០៨ឆ្នាំ (ប្រាំបីឆ្នាំ) ពីបទៈ អំពើកំហែងយកមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ និងបទៈ កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិព្រៃដូនរុក សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហារយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថាៈ

-ទណ្ឌិតឈ្មោះ [redacted] ទិរៈ ហៅ វត្ស ត្រូវបានតុលាការផ្តន្ទាទោស ៨ឆ្នាំ តាមអំណាចសាលដីកាលេខ៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ពីបទ "លួចមានស្ថានទម្ងន់ដោយសារការប្រើអំពើហិង្សា និងការកាន់កាប់អាវុធ



Scanned with CamScanner

ដោយគ្មានការអនុញ្ញាត" និងផ្តន្ទាទោស៨ឆ្នាំ តាមអំណាចសាលដីកាលេខ២២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ពីបទ" កំហែងយកមានស្ថានទម្ងន់ទោស និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត" ។

យល់ឃើញថា បណ្តឹងស្រុបទោសរបស់ទណ្ឌិតឈ្មោះ [redacted] វិរៈ ហៅ រក្ស ធ្វើឡើងស្របតាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ។

តំណាងមហាអយ្យការ ទុកជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់។

-ទណ្ឌិតឈ្មោះ [redacted] វិរៈ បានឆ្លើយថា៖ ខ្ញុំបាទត្រូវបានឃុំខ្លួនថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ នៅពន្ធនាគារ ខេត្តកណ្តាល ។

-លោក [redacted] ថេង ជាមេធាវីការពារឱ្យទណ្ឌិត បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្ញុំបាទត្រូវបានសាលាដំបូង និងសាលាឧទ្ធរណ៍ និងតុលាការកំពូល បានសម្រេចផ្តន្ទាទោស ដោយមានសាលក្រម២ សាលដីកា០២ ១ ដាច់ដោយឡែកពីគ្នា តែមានបទល្មើសតែមួយដូចគ្នា គឺមានបទ អំពើកំហែងយកមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ និងបទ ការកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ហេតុដូចនេះទើបកូនក្តីខ្ញុំប្តឹងសុំអនុវត្តស្រុបទោសបញ្ចូលគ្នា មកតុលាការកំពូល ដើម្បីឱ្យតុលាការកំពូលមេត្តាសម្រេចអនុវត្តស្រុបទោស អោយកូនក្តីខ្ញុំបាទ ចូលក្នុងសាលដីកាតែមួយ នៃការអនុវត្តទណ្ឌកម្ម ក្នុងអតិបរមានៃទោស ស្រុបបញ្ចូលគ្នា។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិតឈ្មោះ [redacted] វិរៈ និងសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីការពារឱ្យទណ្ឌិត

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសុំស្រុបទោស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] វិរៈ ជាទណ្ឌិតធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន។

២-យល់ឃើញថា ពាក្យបណ្តឹងសុំស្រុបទោស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិរៈ ថា ខ្លួនមានសាលដីកាព្រហ្មទណ្ឌស្ថាពររបស់តុលាការកំពូលចំនួន២ ដែលសាលដីកាទី១ មានលេខ៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ មានកំរិតទណ្ឌកម្ម ដាក់ពន្ធនាគារកំណត់៨ឆ្នាំ និងសាលដីកាទី២ លេខ២២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ មានកម្រិតទណ្ឌកម្មដាក់ពន្ធនាគារចំនួន៨ឆ្នាំ ដែលទណ្ឌកម្មសរុបចំនួន១៦ឆ្នាំ។ មូលហេតុដែលខ្លួនសុំស្រុបទោសដោយសារតុលាការកំពូល ដែលសម្រេចចុងក្រោយពុំបានប្រកាសទោសស្រុបបញ្ចូលគ្នា ដែលជាហេតុនាំអោយខ្លួនដាក់ពាក្យសុំ នោះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងរបស់ទណ្ឌិតរូបនេះ មានលក្ខណៈត្រឹមត្រូវតាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣៨ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

ដូច្នេះតុលាការកំពូលគប្បីអនុញ្ញាតអោយស្រូបទោសមួយផ្នែកក្នុងសាលដីកាព្រហ្មទណ្ឌលេខ២២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ទៅក្នុងសាលដីកាព្រហ្មទណ្ឌលេខ៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់តុលាការកំពូល។

៣-យល់ឃើញថា ទណ្ឌិតឈ្មោះ [redacted] វិរៈ ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១។

## ហេតុដូច្នេះ

## សម្រេច

១. ទទួល បណ្តឹងសុំស្រូបទោស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ទិរៈ ។

២. អនុញ្ញាត អោយមានការស្រូបទោសមួយផ្នែកចំនួន៤ឆ្នាំ ដែលបានកំណត់ក្នុងសាលដីកាព្រហ្មទណ្ឌលេខ២២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ របស់តុលាការកំពូល ទៅក្នុងសាលដីកាព្រហ្មទណ្ឌលេខ៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់តុលាការកំពូល។ ដូច្នេះទណ្ឌកម្មដែលទណ្ឌិតឈ្មោះ [redacted] វិរៈ ត្រូវអនុវត្តគឺ១២ឆ្នាំ គិតពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner